ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែវិច្ឆិកា ឆ្នាំ២០២៤

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២៤ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅៈ

## ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១-សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា

- បានបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទី ចំនួន១លើក។

### ១.១.១-សកម្មភាពចូលរួមកិច្ចប្រជុំ

- បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន៣លើក និងសម័យប្រជុំលើកទី២ នីតិកាលទី៥ ព្រឹទ្ធសភា ចំនួន២លើក។

### ១.១.២-បដិសណ្ឋារកិច្ចឡើងជាតិ-អន្តរជាតិ

- **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** បានអនុញ្ញាតឱ្យព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ធម្មិកោ** សមាជិកព្រឹទ្ធសភា ចូលជួបសម្តែងគារវកិច្ច នៅវិមានព្រឹទ្ធសភា។
- **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** បានអនុញ្ញាតឱ្យភ្ញៀវអន្តរជាតិ ចូលជួបសម្តែងការគួរសម សំណេះសំណាល និងពិភាក្សាការងារ ចំនួន១៦លើក រួមមានៈ
  - **ឯកឧត្តម ជិន ថាញ់មិន** (Tran Tranh Man) ប្រធានរដ្ឋសភា នៃសាធារណរដ្ឋសង្គមនិយមវៀតណាម មកបំពេញទស្សនកិច្ចផ្លូវការ និងមិត្តភាព នៅព្រះរាជាណាចក្រកម្ពុជា នៅវិមាន៧មករា។
  - **ឯកឧត្តមនាយឧត្តមសេនីយ៍ ហ្វាន វ៉ាន់ យ៉ាង** (Phan Van Giang) រដ្ឋមន្ត្រីក្រសួងការពារប្រទេស នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅវិមាន៧មករា។
  - **ឯកឧត្តម កៅ គឹមហួន** អគ្គលេខាធិការអាស៊ាន នៅវិមានព្រឹទ្ធសភា។
  - **ឯកឧត្តម តាកាហាស៊ី ហ្វូមីអាគី** (Takahashi Fumiaki) ប្រធានសមាគមជប៉ុន-កម្ពុជា និងគណៈប្រតិភូវិនិយោគជប៉ុន នៅវិមាន៧មករា។
  - **លោក តាន់ ស្រ៊ី ម៉ៃឃើល យ៉េវ** (Tan Sri Michael Yeoh) ប្រធានវិទ្យាស្ថានយុទ្ធសាស្ត្រ



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: secretariat@senate.gov.kh

KSI ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក នៅវិមាន៧មករា។

- **ឯកឧត្តម** Masaharu KOHNO អតីតបេសកជនពិសេសរដ្ឋាភិបាលជប៉ុន នៅវិមាន៧មករា។
- **លោកជំទាវ ថូហ្វីកា ហ៊ុក** (Towfiqua Hoque) តំណាងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា។
- **ឯកឧត្តម អឺមេណេជីលដូ គូប៉ា ឡូប៉េស** (ERMENEGILDO KUPA LOPES) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្ត ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា។
- គណៈប្រតិភូព្រះសង្ឃខ្មែរក្រោម ចំនួន៦ព្រះអង្គ នៃខេត្តត្រាវិញ សាធារណរដ្ឋសង្គមនិយមវៀតណាម ដឹកនាំដោយ**ព្រះតេជព្រះគុណ ថាច់ ញ៉ឹក** ព្រះចៅអធិការវត្តពោធិគិរីវង្សារាម ហៅវត្តស្វាយសៀមថ្មី នៅភូមិគ្រឹះរបស់**សម្តេចតេជោ** នាទីក្រុងតាខ្មៅ ខេត្តកណ្ដាល។

- ជំនួបសម្តែងការគួរសមជាមួយបណ្តាថ្នាក់ដឹកនាំ នៃបណ្តាគណបក្សនយោបាយនៅអាស៊ី ក្នុងឱកាសចូលរួមមហាសន្និបាតសន្និសីទអន្តរជាតិ នៃបណ្តាគណបក្សនយោបាយនៅអាស៊ី (ICAPP) លើកទី១២ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ ចំនួន៤គណៈប្រតិភូគឺ៖
  - **ឯកឧត្តម** Andrés Pastrana ប្រធានអង្គការអ្នកប្រជាធិបតេយ្យនិយមកណ្តាលអន្តរជាតិ CDI-IDC (អតីតប្រធានាធិបតីកូឡុំប៊ី) នៅវិមាន៧មករា។
  - **លោកជំទាវ** Pany Yathotou អនុប្រធានរដ្ឋ នៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ នៅវិមាន៧មករា។
  - **ឯកឧត្តម** Khin Yi ប្រធានគណបក្សសហភាពសាមគ្គី និងអភិវឌ្ឍន៍ (USDP) នៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា សណ្ឋាគារសុខាភ្នំពេញ និង
  - **ឯកឧត្តម** Zafer Sirakaya អនុប្រធានគណបក្សយុត្តិធម៌ និងអភិវឌ្ឍន៍ (AK Parti) នៃសាធារណរដ្ឋតួកគី នៅសណ្ឋាគារសុខាភ្នំពេញ។

- ជំនួបសម្តែងការគួរសមពីសំណាក់បណ្តាថ្នាក់ដឹកនាំនៃសភាអន្តរជាតិ ដើម្បីភាពអត់ឱន និងសន្តិភាព ក្នុងឱកាសចូលរួមសម័យប្រជុំពេញអង្គនៃសភាអន្តរជាតិ ដើម្បីភាពអត់ឱន និងសន្តិភាព លើកទី១១ (IPTP-11th) ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ ចំនួន៣គណៈប្រតិភូ៖
  - ប្រតិភូក្រុមប្រធានសភា នៃប្រទេសជាមិត្ត ដឹកនាំដោយ**ឯកឧត្តម** Dev Raj Ghimire ប្រធានរដ្ឋសភា នៃសាធារណរដ្ឋសហព័ន្ធប្រជាធិបតេយ្យនេប៉ាល់ ដោយមានការចូលរួមពី**លោកជំទាវ** Celmira Saramento **ឯកឧត្តម** Tagesse Chaffo ប្រធានរដ្ឋសភា នៃសាធារណរដ្ឋប្រជាធិបតេយ្យសហព័ន្ធអេត្យូពី និង**ឯកឧត្តមបណ្ឌិត** Moses Wetangíula ប្រធានរដ្ឋសភា នៃសាធារណរដ្ឋកេនយ៉ា នៅវិមាន៧មករា។
  - **ឯកឧត្តម** Ahmed Bin Mohamed Aljarwan ស្ថាបនិក និងជាប្រធានក្រុមប្រឹក្សាសាកលដើម្បីភាពអត់ឱន និងសន្តិភាព នៅវិមាន៧មករា និង
  - **ឯកឧត្តមបណ្ឌិត** Chang Shik Yang ប្រធានសមាគមអន្តរជាតិ នៃសមាជិកសភាដើម្បីសន្តិភាព (IAPP) នៅវិមាន៧មករា។

### ១.១.៣-សកម្មភាពចូលរួមពិធីផ្សេងៗ

- **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** បានអញ្ជើញចូលរួមក្នុងពិធីនានា នៅរាជធានីភ្នំពេញ ចំនួន១៤លើក រួមមាន៖
  - អញ្ជើញដង្ហែព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុត ក្នុងព្រះរាជពិធីខួបអនុស្សាវរីយ៍ខួប ៧១ឆ្នាំ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា នៅវិមានឯករាជ្យ។
  - អញ្ជើញដង្ហែព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុត ក្នុងព្រះរាជពិធីពន្លត់ទៀនជ័យ នៅវិមានឯករាជ្យ។
  - អញ្ជើញដង្ហែព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុត ក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ចំនួន២លើក នៅវេទិកាព្រះពន្លាជ័យ ខាងមុខព្រះបរមរាជវាំង។
  - បានអញ្ជើញចូលរួមថ្វាយព្រះរាជដំណើរព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងទៅបំពេញព្រះរាជទស្សនកិច្ចផ្លូវរដ្ឋ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។
  - បានអញ្ជើញទទួលព្រះរាជដំណើររបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងនិវត្តន៍ពីការបំពេញព្រះរាជទស្សនកិច្ចផ្លូវរដ្ឋ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។
  - បានអញ្ជើញជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា បើកអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេស លើកទី៣២ ប្រចាំឆ្នាំ២០២៤ នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ។
  - បានអញ្ជើញចូលរួមកិច្ចប្រជុំអចិន្ត្រៃយ៍ ICAPP លើកទី១២ នៅសណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ។
  - បានអញ្ជើញជួបសំណេះសំណាល និងពិសាភោជនាហារសាមគ្គីជាមួយក្រុមកីឡាបាល់ទាត់តារាកម្ពុជា និងក្រុមកីឡាប្រដាល់គុនខ្មែរ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍ជ្រោយចង្វារ។
  - បានអញ្ជើញក្នុងពិធីសូត្រមន្ត អង្គកឋិនទានមហាសាមគ្គីគ្រួសារខ្មែរ ដង្ហែទៅកាន់វត្តពោធិគិរីវង្សារាម ខេត្តត្រាវិញ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅវិមាន៧មករា។
  - បានអញ្ជើញទទួលស្វាគមន៍បណ្តាថ្នាក់ដឹកនាំគណបក្សនយោបាយនានា មុនពិធីបើកមហាសន្និបាត ICAPP លើកទី១២ នៅវិមាន៧មករា។

- បានអញ្ជើញចូលរួមជាអធិបតី និងផ្តល់សុន្ទរកថាពិសេស ក្នុងពិធីបើកមហាសន្និបាត ICAPP លើកទី១២ នៅវិមាន៧មករា។
- បានអញ្ជើញចូលរួមក្នុងពិធីជប់លៀង (Gala Dinner) ជូនដល់បណ្តាប្រតិភូថ្នាក់ដឹកនាំគណបក្សនយោបាយនានាដែលបានអញ្ជើញចូលរួមនៅក្នុងមហាសន្និបាត ICAPP លើកទី១២ នៅសណ្ឋាគារសុខាភ្នំពេញ។
- បានអញ្ជើញទទួលស្វាគមន៍បណ្តាថ្នាក់ដឹកនាំ IPTP លើកទី១១ នៅសណ្ឋាគារសុខាភ្នំពេញ។
- បានអញ្ជើញជាអធិបតីក្នុងពិធីបើក និងផ្តល់បាឋកថាពិសេសក្នុងសម័យប្រជុំពេញអង្គ IPTP លើកទី១១ និងអញ្ជើញទទួលពានរង្វាន់ " មេដាយសន្តិភាព ដើម្បីមនុស្សជាតិ និងភពផែនដី " នៅសណ្ឋាគារសុខាភ្នំពេញ។

### ១.១.៤-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

- បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន៧៧ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន១០៩ច្បាប់។

## ១.២-ឯកឧត្តម ប្រាក់ សុខុន អនុប្រធានទី១ព្រឹទ្ធសភា

### ១.២.១-សកម្មភាពចូលរួមកិច្ចប្រជុំ

- បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន២លើក។
- បានអញ្ជើញដឹកនាំប្រជុំការងារផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅបន្ទប់ប្រជុំរបស់ឯកឧត្តម។
- បានអញ្ជើញដឹកនាំប្រជុំគណៈកម្មការរៀបចំមហាសន្និបាត ICAPP លើកទី១២ និងកិច្ចប្រជុំពាក់ព័ន្ធ ដែលកម្ពុជាត្រៀមធ្វើជាម្ចាស់ផ្ទះ និង
- បានអញ្ជើញដឹកនាំប្រជុំពិភាក្សាត្រួតពិនិត្យវឌ្ឍនភាពការងារ និងប្រតិទិនការងារសាងសង់អគារថ្មីព្រឹទ្ធសភា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។

### ១.២.២-បដិសណ្ឋារកិច្ចឡៀវជាតិ-អន្តរជាតិ

- បានអនុញ្ញាតឱ្យ**ឯកឧត្តម គី តិច** ប្រធានក្រុមមេធាវីរាជរដ្ឋាភិបាល និងជាប្រធានក្រុមមេធាវីស្ម័គ្រចិត្ត**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅបន្ទប់ប្រជុំរបស់ឯកឧត្តម។
- បានអនុញ្ញាតឱ្យ**ឯកឧត្តម អឺមេនេជីលដូ កូប៉ា ឡូប៉េស** (Ermenegildo Kupa Lopes) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅបន្ទប់ទទួលភ្ញៀវរបស់ឯកឧត្តម។
- បានអញ្ជើញអមសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន ប្រធានព្រឹទ្ធសភា** អនុញ្ញាតឱ្យ**ឯកឧត្តម វ៉ាង វិនប៊ីន** (Wang Wenbin) ឯកអគ្គរដ្ឋទូត នៃសាធារណៈរដ្ឋប្រជាមានិតចិន

ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅភូមិគ្រឹះ**សម្តេច** ក្នុងក្រុងតាខ្មៅ និង

- បានអនុញ្ញាតឱ្យ**លោកស្រី នីណូ ប៊ូចាសវីលី** (Nino BUJIASHVILI) ប្រធាននាយកដ្ឋានជំនាញកិច្ចការអន្តរជាតិ នៃសភា G'eorgie ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ។

### ១.២.៣-សកម្មភាពចូលរួមពិធីផ្សេងៗ

- បានអញ្ជើញចូលរួមព្រះរាជពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៧១ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើត នៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២៤ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានឯករាជ្យ។
- បានអញ្ជើញជាអធិបតីបើកសិក្ខាសាលាការផ្លាស់ប្តូរព័ត៌មានក្នុងស្ថាប័នសភាស្តីពី " តួនាទី និងសមត្ថកិច្ចក្នុងសេវាកម្មស្រាវជ្រាវនៅសភា " នៅសាលខាងជើង វិមានព្រឹទ្ធសភា។
- បានអញ្ជើញបំពាក់គ្រឿងឥស្សរិយយសរបស់សភាប្រើកាសាបារាំង ជូនសមាជិកសភាកម្ពុជា និងអ្នកសារព័ត៌មាន នៅវិមានព្រឹទ្ធសភា។
- បានអញ្ជើញចូលរួមពិធីក្រុងពាលី នមស្ការព្រះរត្នត្រ័យ សមាទានសីល ចម្រើនព្រះបរិត្ត នៃអង្គកឋិនទានមហាសាមគ្គីគ្រួសារខ្មែរ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា** នៅវិមាន៧មករា។
- បានអញ្ជើញផ្តល់បទសម្ភាសន៍ ជាមួយទូរទស្សន៍ជាតិកម្ពុជា(ទទក) អំពីការរៀបចំមហាសន្និបាត ICAPP លើកទី១២ និងកិច្ចប្រជុំពាក់ព័ន្ធ ដែលកម្ពុជាត្រៀមធ្វើជាម្ចាស់ផ្ទះ។
- បានអញ្ជើញជាអធិបតីក្នុងពិធីចុះអនុស្សរណៈ នៃការយោគយល់(MOU) រវាងគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត នៃព្រឹទ្ធសភា ជាមួយក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន នៅវិមានព្រឹទ្ធសភា និង
- បានអញ្ជើញជាអធិបតីថ្លែងសុន្ទរកថាស្វាគមន៍ ក្នុងពិធីលៀងសាយភោជន៍ (Gala Dinner) នៃកិច្ចប្រជុំកំពូលសេដ្ឋកិច្ច និងបច្ចេកវិទ្យាចិនសកល ឆ្នាំ២០២៤ និងកិច្ចប្រជុំកំពូលសេដ្ឋកិច្ចអាស៊ី និងភាពជាសហគ្រិន ឆ្នាំ២០២៤។

### ១.២.៤-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

- បានចុះហត្ថលេខាលើសេចក្តីសម្រេច ចំនួន១ច្បាប់ និង
- បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន៧១ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន១៥ច្បាប់។

## ១.៣-ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី២ព្រឹទ្ធសភា

### ១.៣.១-សកម្មភាពចូលរួមកិច្ចប្រជុំ

- បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន៣លើក និងសម័យប្រជុំលើកទី២ព្រឹទ្ធសភា ចំនួន២លើក។

- បានអញ្ជើញដឹកនាំសម័យប្រជុំពេញអង្គ IPTP លើកទី១១ វគ្គទី១ ស្តីពីការជំរុញនិម្មាបនកម្ម សកលដើម្បីសន្តិភាព ការកសាងសន្តិភាព ការផ្សះផ្សា និងភាពអត់ឱនៈ សហថាមពលរបស់ រដ្ឋាភិបាល សភា និងសង្គមស៊ីវិល នៅសណ្ឋាគារសុខាភ្នំពេញ។

### ១.៣.២-បដិសណ្ឋារកិច្ចថ្នាក់ជាតិ-អន្តរជាតិ

- បានអនុញ្ញាតឱ្យឯក**ឧត្តម ហ្សេហ្វឺ ស៊ីរ៉ាកាយ៉ា** (Zafer SIRAKAYA) អនុប្រធានគណបក្ស យុត្តិធម៌ និងអភិវឌ្ឍន៍ (AK Parti) និងជាប្រធានទទួលបន្ទុកកិច្ចការបរទេសសាធារណរដ្ឋ តួកគី ចូលជួបសម្តែងការគួរសម នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។

### ១.៣.៣-សកម្មភាពចុះមូលដ្ឋាន

- បានចាត់ឯក**ឧត្តម ជឹម លាវ** សមាជិកព្រឹទ្ធសភាប្រចាំមណ្ឌលភូមិភាគទី២ និងថ្នាក់ដឹកនាំ សមាជិកខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នៃសមាគមបេសកកម្ម សិក្សាអាស៊ី (AMS) ដើម្បីចុះពិនិត្យ និងព្យាបាលជំងឺដោយឥតគិតថ្លៃជូន ប្រជាពលរដ្ឋ ចំនួន ២០០នាក់ (ស្ត្រី ១២៨នាក់) ក្នុងបរិវេណ នៃមន្ទីរពេទ្យបង្អែក ហ៊ុន សែន ស្ទឹងត្រង់ ស្រុក ស្ទឹងត្រង់ ខេត្តកំពង់ចាម។

### ១.៣.៤-សកម្មភាពចូលរួមពិធីផ្សេងៗ

- បានអញ្ជើញចូលរួមក្នុងព្រះរាជពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៧១ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើត នៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២៤ក្រោមព្រះរាជាធិបតីភាព ដ៏ខ្ពង់ខ្ពស់បំផុត**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានឯករាជ្យ។
- បានអញ្ជើញចូលរួមដង្ហែ**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហា ក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងព្រះរាជពិធីពន្លត់ភ្លើងជ័យ នាឱកាសប្រារព្ធព្រះរាជពិធី បុណ្យខួបអនុស្សាវរីយ៍លើកទី៧១ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតនៃកង យោធពលខេមរភូមិន្ទ ឆ្នាំ២០២៤ នៅវិមានឯករាជ្យ។
- បានដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជាថ្វាយកម្រងផ្កា និងគោរពព្រះវិញ្ញាណក្ខន្ធ**ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "**ព្រះបរមរតនកោដ្ឋ**" ក្នុងឱកាសបុណ្យខួបអនុស្សាវរីយ៍លើកទី៧១ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២៤ នៅមណ្ឌបសួនច្បារខាងកើតវិមានឯករាជ្យ។
- បានដឹកនាំគណៈប្រតិភូព្រឹទ្ធសភាអញ្ជើញដាក់កម្រងផ្កា និងគោរពវិញ្ញាណក្ខន្ធបុព្វការីជន ក្នុង ឱកាសបុណ្យខួបអនុស្សាវរីយ៍ លើកទី៧១ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើត នៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២៤ នៅវិមានឯករាជ្យ។
- បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីពិសាភោជនាហារសាមគ្គីជាមួយក្រុមកីឡាបាល់ ទាត់តារាកម្ពុជា និងក្រុមកីឡាប្រដាល់គុនខ្មែរ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេច**

**អគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** នៅមជ្ឈមណ្ឌលសន្និសីទ OCIC ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

- បានអញ្ជើញចូលរួមក្នុងពិធីបិទសម័យប្រជុំពេញអង្គ IPTP លើកទី១១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភា** និងជាប្រធានសម័យប្រជុំពេញអង្គ IPTP លើកទី១១ នៅសណ្ឋាគារសុខាភ្នំពេញ។
- បានអញ្ជើញចូលរួមទទួលទានអាហារស្វាគមន៍គណៈប្រតិភូ ដែលអញ្ជើញចូលរួមមហាសន្និបាត ICAPP លើកទី១២ និងកិច្ចប្រជុំពាក់ព័ន្ធ នៅសណ្ឋាគារហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ។
- បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីទទួលទានអាហារស្វាគមន៍គណៈប្រតិភូ នៃប្រទេសនានា ដែលអញ្ជើញចូលរួមសម័យប្រជុំពេញអង្គ IPTP លើកទី១១ នៅសណ្ឋាគារសុខាភ្នំពេញ។
- បានអញ្ជើញចុះហត្ថលេខាគាំទ្រលើ " ធម្មនុញ្ញសកលៈ ដើម្បីមនុស្សជាតិ និងភពផែនដី " ក្នុងក្របខ័ណ្ឌ នៃសម័យប្រជុំពេញអង្គ IPTP លើកទី១១ នៅសណ្ឋាគារសុខាភ្នំពេញ។
- បានអញ្ជើញចូលរួមក្នុងពិធីប្រកាសចូលកាន់តំណែងរបស់**ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង
- បានអញ្ជើញចូលរួមសិក្ខាសាលាការផ្លាស់ប្តូរព័ត៌មានក្នុងស្ថាប័នសភាស្តីពី "តួនាទី និងសមត្ថកិច្ចក្នុងសេវាកម្មស្រាវជ្រាវនៅសភា " ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តម ប្រាក់ សុខុន អនុប្រធានទី១ព្រឹទ្ធសភា** នៅសាលខាងជើង វិមានព្រឹទ្ធសភា។

### ១.៣.៨-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

- បានពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ចំនួន៣ច្បាប់។
- បានពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងសេចក្តីសម្រេច ចំនួន៣ច្បាប់។
- បានចុះហត្ថលេខាលើលិខិតស្នើយោបល់ និងលិខិតផ្សេងៗ ចំនួន២៧ច្បាប់។
- បានពិនិត្យលើឯកសារចូល ចំនួន៥៥ច្បាប់ និង
- ឯកសារស្រាវជ្រាវ-វិភាគព័ត៌មាន ចំនួន២៦ច្បាប់។

## ២-សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

ព្រឹទ្ធសភាបានបើកកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចំនួន៣លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** ដើម្បីពិនិត្យសំណើរបស់រដ្ឋសភា និងពិនិត្យសម្រេចលើសំណើរបស់គណៈកម្មការជំនាញ លើសេចក្តីព្រាងច្បាប់ ចំនួន៣ច្បាប់ និងសំណើរបស់គណបក្សប្រជាជនកម្ពុជាលេខៈ០៧១/១១២៤/លគ.គក ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៤ ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី២ព្រឹទ្ធសភា។

## ៣-សម័យប្រជុំពេញអង្គព្រឹទ្ធសភា

ព្រឹទ្ធសភាបានបើកសម័យប្រជុំលើកទី២ នីតិកាលទី៥ ចំនួន២លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** ដែលមានរបៀបវារៈ ដូចខាងក្រោម៖

១-ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តលុបចោលកិច្ចព្រមព្រៀងស្តីពី ការជំរុញ និងសម្រួលពាណិជ្ជកម្មតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម។

២-ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃកិច្ចព្រមព្រៀងស្តីពី ការទទួលយកបទប្បញ្ញត្តិបច្ចេកទេសរួម នៃអង្គការសហប្រជាជាតិសម្រាប់យានយន្ត បរិក្ខារ និងគ្រឿងបន្លាស់ដែលអាចបំពាក់ និងប្រើប្រាស់ទៅលើយានយន្ត និងលក្ខខណ្ឌសម្រាប់ការទទួលស្គាល់ទៅវិញទៅមក នៃការផ្តល់អនុលោមភាពដោយឈរលើមូលដ្ឋាន នៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិ។

៣-ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ប្រព័ន្ធទឹកកខ្វក់។

៤-ប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី។

៥-បោះឆ្នោតជ្រើសរើសអនុប្រធានទី១ និងអនុប្រធានទី២ព្រឹទ្ធសភា នីតិកាលទី៥។

៦-បោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការទី២ព្រឹទ្ធសភា នីតិកាលទី៥ និង

៧-ផ្សេងៗ។

## ៤-គណៈកម្មការនានារបស់ព្រឹទ្ធសភា

សមាជិក សមាជិកាព្រឹទ្ធសភាបានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ៤.១-មុខងារនីតិកម្ម

- បានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការជាមួយតំណាងរាជរដ្ឋាភិបាលដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ ចំនួន៣ច្បាប់។

### ៤.២-មុខងារតំណាង

- បានទទួលពាក្យបណ្តឹងចូល ចំនួន១បណ្តឹង ធ្វើកំណត់បង្ហាញពាក្យបណ្តឹង ចំនួន៧បណ្តឹង ផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹង ចំនួន៧បណ្តឹង បញ្ជូនពាក្យបណ្តឹងចេញទៅក្រសួង ខេត្ត និងស្ថាប័នពាក់ព័ន្ធ ចំនួន៦បណ្តឹង កំពុងពិនិត្យសិក្សា ចំនួន១បណ្តឹង រំលឹកជំរុញដោះស្រាយពាក្យបណ្តឹង ចំនួន១បណ្តឹង។
- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅវេទិកាព្រះពន្លាជ័យ ខាងមុខព្រះបរមរាជវាំង។
- បានអញ្ជើញចូលរួមប្រារព្ធព្រះរាជពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៧១ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើត នៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២៤ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅវិមានឯករាជ្យ។

- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីពន្លត់ភ្លើងជ័យ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅវិមានឯករាជ្យ។
- បានអញ្ជើញចូលរួមក្នុងពិធីដាក់កម្រងផ្កា និងគោរពវិញ្ញាណក្ខន្ធបុព្វការីជន ក្នុងឱកាសបុណ្យអនុស្សាវរីយ៍ លើកទី៧១ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើត នៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០២៤ ថ្វាយកម្រងផ្កា និងគោរពព្រះវិញ្ញាណក្ខន្ធ**ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "**ព្រះបរមរតនកោដ្ឋ**" ដឹកនាំដោយ**ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី២ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នៅមណ្ឌបតម្កល់ព្រះបរមរូប សួនច្បារខាងកើតវិមានឯករាជ្យ រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមពិធីបើកអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេស លើកទី៣២ ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយស ក្នុងពិធីសំណេះសំណាល និងពិសាភោជនាហារសាមគ្គី ជាមួយក្រុមកីឡាបាល់ទាត់តារាកម្ពុជា និងក្រុមកីឡាប្រដាល់គុនខ្មែរ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិ ជ្រោយចង្វារ (OCIC) អគារD រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមក្នុងពិធីសូត្រមន្តអង្គកឋិនទានមហាសាមគ្គីគ្រួសារខ្មែរ ដង្ហែទៅកាន់វត្តពោធិគិរីវង្សារាម ខេត្តត្រាវិញ សាធារណរដ្ឋសង្គមនិយមវៀតណាម នៅវិមាន៧មករា។
- បានអញ្ជើញចូលរួមក្នុងកម្មវិធីសិក្ខាសាលាស្តីពី "ការកសាងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់រៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០២៥" រៀបចំដោយគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុធនាគារ និងសវនកម្ម នៃរដ្ឋសភា ក្រោមអធិបតីភាព**ឯកឧត្តម ឈាង វុន** ប្រធានគណៈកម្មការទី២រដ្ឋសភា នៅសាលសន្និសីទបាយ័ន វិមានរដ្ឋសភា។
- បានអញ្ជើញចូលរួមវេទិកាពិសេសស្តីពី "សន្តិភាពសម្រាប់មនុស្សជាតិ និងភពផែនដី" និងកិច្ចពិភាក្សាស្តីពី "ធម្មនុញ្ញសន្តិភាព ដើម្បីមនុស្សជាតិ និងភពផែនដី" នៅសណ្ឋាគារ Raffles Grand Hotel d'Angkor ខេត្តសៀមរាប។
- បានអញ្ជើញចូលរួមពិធីបើក និងបិទសិក្ខាសាលាការផ្លាស់ប្តូរព័ត៌មានក្នុងស្ថាប័នសភា ស្តីពីតួនាទី និងសមត្ថកិច្ចក្នុងសេវាកម្មស្រាវជ្រាវនៅសភា និងពិធីបំពាក់គ្រឿងឥស្សរិយយស (Ordre de la Pléiade) របស់សភាប្រើភាសាបារាំង ជូនសមាជិកសភាកម្ពុជា និងអ្នកសារព័ត៌មាន ក្រោមអធិបតីភាព**ឯកឧត្តម ប្រាក់ សុខុន** អនុប្រធានទី១ព្រឹទ្ធសភា ប្រធានក្រុមសភាជាតិកម្ពុជា និងជាអនុប្រធានសភាប្រើភាសាបារាំង (APF) នៅសាលខាងជើង វិមានព្រឹទ្ធសភា។
- បានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នៃសមាគមបេសកកម្មសិក្សាអាស៊ីរបស់ប្រទេសបារាំង ចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅស្រុកប្រាសាទបាគង ខេត្តសៀមរាប។

- បានអញ្ជើញដឹកនាំគណៈប្រតិភូមកពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ វិទ្យាស្ថានជាតិកសិកម្ម ព្រែកលៀប សមាគមនិស្សិតខ្មែរមកពីប្រទេសជប៉ុន និងវិស័យឯកជន ទស្សនកិច្ចសិក្សាស្វែងយល់អំពីស្ថានភាពសេដ្ឋកិច្ចរបស់វិស័យកសិ-ឧស្សាហកម្ម នៅតំបន់អភិវឌ្ឍន៍ **ឧកញ៉ា ម៉ុង ឫទ្ធី** ស្រុកកំពង់សីលា ខេត្តព្រះសីហនុ។
- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ ចំនួន៥លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា រួមមានៈ ពិធីបើកការប្រកួតកីឡាជាតិលើកទី៤ និងកីឡាជាតិជនពិការ លើកទី២ ឆ្នាំ២០២៤, ពិធីសម្ពោធឱ្យប្រើជាផ្លូវការ វិថីតេជោសន្តិភាព ឆ្មេរអង្គោល ប្រវែង១២.៦៤៥ ម៉ែត្រ, ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការទំនប់អូរតេធិបតី ទំនប់សែនសុខដុម និងទំនប់សែនមនោរម្យ, ពិធីសំណេះសំណាល និងបំពាក់កន្សែងយុវជនកាកបាទក្រហមកម្ពុជា មកពីគ្រឹះស្ថានឧត្តមសិក្សាចំនួន២៥ ក្នុងរាជធានីភ្នំពេញ, ពិធីបិទអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី៣២ ឆ្នាំ២០២៤ នៅរាជធានីភ្នំពេញ ខេត្តកែប និងខេត្តមណ្ឌលគិរី និង
- សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន យុវជន យុវនារី ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ នៅមូលដ្ឋាន ស្វែងយល់អំពីវឌ្ឍនភាពការងារ សន្តិសុខសណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអនុវត្តគោលនយោបាយនានា ពិនិត្យហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅរាជធានី និងតាមបណ្តាខេត្តនានា ចំនួន៣៩ លើក ព្រមទាំងបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធសមិទ្ធផលនានា និងពិធីផ្លូវការផ្សេងៗ ចំនួន១៥៧លើក។

## ៤.៣-កិច្ចសហប្រតិបត្តិការអន្តរជាតិ

សមាជិក សមាជិកាព្រឹទ្ធសភា បានចូលរួមយ៉ាងសកម្មក្នុងការងារសហប្រតិបត្តិការអន្តរជាតិរបស់ព្រឹទ្ធសភា ជាពិសេសទំនាក់ទំនងក្នុងកម្រិតតំបន់ និងអន្តរជាតិ និងទទួលបានលទ្ធផលជាវិជ្ជមានដូចខាងក្រោមៈ

- សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីបើកសម័យប្រជុំពេញអង្គ IPTP លើកទី១១ ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** នៅសណ្ឋាគារសុខាភ្នំពេញ។
- សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីទទួលពានរង្វាន់ "**សន្តិភាពដើម្បីមនុស្សជាតិ និងភពផែនដី**" ពីឯកឧត្តម Ahmed bin Mohamed Aljarwan ប្រធានក្រុមប្រឹក្សាសកលសម្រាប់ការអត់ឱន និងសន្តិភាព (GCTP) ជូន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** ក្នុងសម័យប្រជុំពេញអង្គ IPTP លើកទី១១ នៅសណ្ឋាគារសុខាភ្នំពេញ។

- **ឯកឧត្តមបណ្ឌិត ចែម វីឡា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា៖
  - បានអញ្ជើញបន្តចូលរួមសម័យប្រជុំពេញអង្គលើកទី១ ដើម្បីពិភាក្សា និងអនុម័តទៅលើរបៀបវារៈមួយចំនួនដូចជា កម្មវិធី របៀបវារៈ ប្រធានបទ និងកិច្ចការនានាដែលពាក់ព័ន្ធនឹងសកម្មភាពទាំងឡាយ ក្នុងកំឡុងពេលមហាសន្និបាតអាយប៉ាលើកទី៤៥ (AIPA-45th) និងព័ត៌មានបឋមមួយចំនួនទាក់ទងនឹងការរៀបចំអាយប៉ាលើកទី៤៦ និង៤៧ ព្រមទាំងក្រុមប្រឹក្សាពិគ្រោះយោបល់ស្តីពីគ្រឿងញៀន (AIPA-CODD) លើកទី៨ សម័យប្រជុំពេញអង្គលើកទី១ នោះ ប្រព្រឹត្តទៅក្រោមអធិបតីភាព**ឯកឧត្តម សៃស៊ុមផន កុមវិហាន** (Saysomphone Phomvihane) ប្រធានរដ្ឋសភាឡាវ និងជាប្រធានអាយប៉ា នៅទីក្រុងវៀងចន្ទន៍ សាធារណរដ្ឋប្រជាមានិតឡាវ។
  - បានអនុញ្ញាតឱ្យ**ឯកឧត្តម Igor Driesmans** ឯកអគ្គរដ្ឋទូត នៃស្ថានបេសកកម្មសហភាពអឺរ៉ុប ប្រចាំព្រះរាជាណាចក្រកម្ពុជា ទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅសាលប្រជុំគណៈកម្មការទី៥ អគារE1។
  - បានអញ្ជើញចូលរួមកម្មវិធីប្រគុំតន្ត្រីព្យាណូបុរាណដោយ**លោក Lee Jea Phang** ក្រោមការអញ្ជើញរបស់**ឯកឧត្តម Stefan Messerer** ឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅលំនៅដ្ឋានរបស់ឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ រាជធានីភ្នំពេញ និង
  - បានអញ្ជើញចូលរួមកម្មវិធីប្រគុំតន្ត្រីរបស់ក្រុមជនជាតិរុស្ស៊ី " Turetsky Choir " និង SOPRANO ក្រោមការអញ្ជើញរបស់**ឯកឧត្តម Anatoly Borovik** ឯកអគ្គរដ្ឋទូតរុស្ស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅ The Club នៃស្ថានទូតរុស្ស៊ី រាជធានីភ្នំពេញ។
- **ឯកឧត្តមបណ្ឌិត ចែម វីឡា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា **ឯកឧត្តម អ៊ុំ សារិទ្ធ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានអនុញ្ញាតឱ្យ**លោកស្រី Nino BUJIASHVILI** ប្រធាននាយកដ្ឋានជំនាញកិច្ចការអន្តរជាតិ និងជាម្ចាស់ពានរង្វាន់ Geoffrey-Dieudonné នៃសភាប្រើភាសាបារាំង (APF) ប្រចាំឆ្នាំ២០២៣ ចូលជួបសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា។
- **ឯកឧត្តមបណ្ឌិត ចែម វីឡា** ប្រធានគណៈកម្មការទី៥ ព្រឹទ្ធសភា **លោកជំទាវបណ្ឌិត ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា និងជាអនុប្រធានក្រុមអន្តរសភាអាស៊ាន(AIPA) **ឯកឧត្តម អាយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា និងជាសមាជិកក្រុមអន្តរសភាអាស៊ាន (AIPA) បានអញ្ជើញចូលរួមមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៥ (AIPA-45th) ក្រោមប្រធានបទ " The Role of Parliaments in Enhancing Connectivity and Inclusive Growth of ASEAN " ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់**សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា នៅទីក្រុងវៀងចន្ទន៍ សាធារណរដ្ឋប្រជាមានិតឡាវ។
- **ឯកឧត្តម ងី ច័ន្ទផល** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីបិទ និងពិធីលៀងសាយភោជន៍( Gala Dinner) នាសម័យប្រជុំពេញអង្គលើកទី១១ នៃសភាអន្តរជាតិ ដើម្បីភាពអត់ឱន និងសន្តិភាព ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា និងជាប្រធានសម័យប្រជុំពេញអង្គ IPTP លើកទី១១ នៅសណ្ឋាគារសុខាភ្នំពេញ។
- **ឯកឧត្តម ឆាយ វណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញជូន និងទទួលដំណើរ គណៈប្រតិភូ ចំនួន៧០រូប ធ្វើដំណើរទេស្សនកិច្ច និងអុំពោះ (រុក្ខហាជីអុំពោះ) នៅ

ព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត តាមរយៈសមាគមប្រភពល្អកម្ពុជា នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។

- **ឯកឧត្តម គង់ មុនីកា** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយ ឯកអគ្គរាជទូតចក្រភពអង់គ្លេស ប្រចាំព្រះរាជាណាចក្រកម្ពុជាស្តីពី សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យនៅប្រទេសកម្ពុជា នៅស្ថានទូតចក្រភពអង់គ្លេស។
- **ឯកឧត្តម សុក ហាច** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញចូលរួមតាមដានមើលការបោះឆ្នោតជ្រើសរើសប្រធានាធិបតីសហរដ្ឋអាមេរិកលើកទី៤៧ នៅគេហដ្ឋានឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក លេខ៩៦ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ។

ថ្ងៃ សុក្រ ១៣ កើត ខែ មិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨<br>
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០២៤

**ប្រធានស្តីទីព្រឹទ្ធសភា**

Vathana

**បណ្ឌិត ធន់ វឌ្ឍនា**

<u>ចម្លងជូន៖</u>

- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
  (ជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ